អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សកម្មភាពផ្សព្វផ្សាយរបស់អង្គភាពជនរងគ្រោះ នៅខេត្តកំពង់ចាម និងខេត្តពោធិ៍សាត់

## វេទិកាប្រចាំតំបន់នៅខេត្តកំពង់ចាម

"យើងចង់បានយុត្តិធម៌"

គឺជាចម្លើយដ៏ច្រើនលើសលុបពីសំណាក់អ្នកចូលរួមក្នុងវេទិកាប្រចាំ តំបន់ រៀបចំឡើងនៅខេត្តកំពង់ចាម ថ្ងៃទី២៤-២៥ ខែតុលា ខណៈដែលពួកគេត្រូវបានសួរពីមូលហេតុដែលពួកគេចង់ចូលរួមក្នុងការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាង១៦០នាក់មកពីខេត្តកំពង់ចាម, ព្រៃវែង, ស្វាយរៀង, ក្រចេះ និងស្ទឹងត្រែងបានចូលរួមក្នុងវេទិកាប្រចាំតំបន់លើកទីពីររៀបចំដោយអង្គភាពជនរងគ្រោះនៃអវតក។ វេទិកានេះត្រូវបានកត់សម្គាល់ឃើញថាមានការពិភាក្សា យ៉ាងរស់រវើកក្នុងចំណោមអ្នកចូលរួម ហើយសំនួរដ៏គួរឲ្យចាប់អារម្មណ៍ជាច្រើនត្រូវបានលើកឡើងដល់វាគ្មិនកិត្តិយស បន្ទាប់ពីការធ្វើបទបង្ហាញអំពីសិទ្ធិជនរងគ្រោះ និងដំណើរការនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបច្ចុប្បន្នភាពនៃកិច្ចស៊ើបអង្កេត។

ភ្ញៀវពិសេស នៅថ្ងៃទីមួយនៃវេទិកាគឺ លោក យិន ប៊ុនទិត អគ្គលេខាធិការសាលាខេត្តកំពង់-ចាម ដែលលោកបានថ្លែងសន្ទរកថាបើកវេទិកានេះ ជួសមុខឲ្យឯកឧត្តមអភិបាលខេត្ត ហ៊ុន ណេង។ លោកស្រីបណ្ឌិត ហេឡិន ចារវិស ប្រធានអង្គភាពជនរងគ្រោះ បានស្វាគមន៍អ្នកចូលរួមទាំងអស់ និងបង្ហាញអំពីការអភិវឌ្ឍថ្មីៗរបស់តុលាការ ក្នុងនោះរួមមានការជំនុំជម្រះជនជាប់ចោទ កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ។ លោកស្រីបណ្ឌិតបានរាយការណ៍បន្ថែមថា កន្លងមកនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៧១នាក់ហើយ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកស្រីបណ្ឌិតបានសង្កត់បន្ថែមលើសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះក្នុងការជំនុំជម្រះ និងប្តេជ្ញាថា អង្គភាពជនរងគ្រោះនឹងបន្តខិតខំប្រឹងប្រែងឲ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីធានាថា

ជនរងគ្រោះអាចចូលរួមប្រកបដោយអត្ថន័យក្នុងការជំនុំជម្រះ ហើយផលប្រយោជន៍ពួកគេត្រូវបានការពារយ៉ាងសមស្របដោយមេធាវី។

វាគ្មិនបានផ្តល់ព័ត៌មានអំពីការិយាល័យសហចៅក្រមស៊ើបសង្កេត អង្គភាពជនរងគ្រោះ ការិយាល័យសហព្រះរាជអាជ្ញា និងគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ។ អ្នកចូលរួមបានលើកឡើងនូវសំនួរសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ហេតុអ្វីបានជាការជំនុំជម្រះប្រើពេលវេលាយូរម្លេះ?
- តើការជំនុំជម្រះរបស់អវតកមានយុត្តិធម៌សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទេ? ហេតុអ្វី?
- ចុះគិតយ៉ាងម៉េចវិញជាមួយនឹង កម្មាភិបាលថ្នាក់ក្រោមរបស់ខ្មែរក្រហម ដែលបានសម្លាប់មនុស្សជាច្រើន ហើយកំពុងរស់នៅក្នុងសហគមន៍សព្វថ្ងៃនេះ?
- ហេតុអ្វីបានជាចោទប្រកាន់តែប្រាំនាក់?
- តើព័ត៌មានអ្វីខ្លះ ដែលយើងត្រូវបំពេញក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ?
- តើដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងអស់នឹងទទួលបានសំណងអ្វីខ្លះ?
- តើសហគមន៍អន្តរជាតិដឹងអំពីទុក្ខវេទនារបស់យើងក្នុងរបបខ្មែរក្រហមទេ ឬក៏គេទើបតែដឹង ក្រោយមក?
- តើនឹងមានការចោទប្រកាន់ជនបរទេសណាទេ?
- ហេតុអ្វីបានជាជនរងគ្រោះមិនមានសិទ្ធិទទួលបានសំណងជាលក្ខណៈបុគ្គល?

ក្នុងពេលពិភាក្សាជាក្រុមតូចៗ អ្នកចូលរួមបានលើកឡើងអំពីមូលហេតុដែលខ្លួនចង់ចូលរួមក្នុងការជំនុំជម្រះ និងការរំពឹងទុករបស់ពួកគេពីដំណើរការនេះ។ ពួកគេក៏បានសង្កត់ធ្ងន់លើតម្រូវការផ្នែកមេធាវី ដែលនឹងតំណាងឲ្យផលប្រយោជន៍របស់ពួកគេ និងផ្តល់ដំណឹងដល់ពួកគេ។ ពួកគេបាន ផ្តល់ជាយោបល់ជាច្រើន ដែលអង្គភាពជនរងគ្រោះ និងអវតក អាចផ្តល់ព័ត៌មានដល់ពួកគេ ក្នុងនោះមានការផ្សព្វផ្សាយតាមទូរទស្សន៍ឲ្យបានច្រើនស្ថានីយ, ទំនាក់ទំនងតាមបណ្តាញទូរស័ព្ទ និងការចុះដល់សហគមន៍ផ្ទាល់។

នៅថ្ងៃទីពីរ អ្នកចូលរួមទទួលឱកាសជួបជាមួយមេធាវីជាតិ និងអន្តរជាតិប្រាំបួនរូប ដែលនឹងត្រូវតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២។

មេធាវីភាគច្រើននឹងតំណាងឲ្យក្រុម ជនរងគ្រោះជាក់លាក់ ដូចជា ក្រុមជនរងគ្រោះពីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងយ៉េនឌ័រ, ការរំលោភបំពានទៅលើសាសនា ឬជនជាតិភាគតិច, ការជម្លៀសដោយបង្ខំ និងការឃុំឃាំង និងការធ្វើទារុណកម្ម។

លោកស្រី ជុំ នៅ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងសំណុំរឿង០០១ បានជម្រាបដល់អ្នកចូលរួមថា លោកស្រីធ្លាប់យំរាល់ពេលដែលលោកស្រីនិយាយអំពីបទពិសោធន៍របស់លោកស្រីនៅសម័យខ្មែរក្រហម។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានចូលរួមក្នុងការជំនុំជម្រះ ហើយដោយមាន ការជួយគាំទ្រផ្នែកផ្លូវចិត្តពីអង្គការធីភីអូ ឥឡូវលោកស្រីអាចនិយាយនៅទីសាធារណៈដោយមិនយំ។ លោកស្រី បានជម្រាបដល់អ្នកចូលរួមថា ជាការសំខាន់ណាស់សម្រាប់លោកស្រីក្នុងការអង្គុយក្នុង កៅអីមួយ ក្នុងចំណោមកៅអីទាំងដប់ បម្រុងទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសាលសវនាការ។ លោកស្រីបានពិពណ៌នាអំពីការលំបាកក្នុងការនិយាយក្នុងតុលាការ ពិសេសដោយមានការឈប់សម្រាករយៈពេលបួនថ្ងៃចំកណ្តាលពេលលោកស្រីផ្តល់សក្ខីកម្ម ហើយលោកស្រីបន្ថែមទៀតថា លោកស្រីយំច្រើនណាស់ក្នុងពេលនោះ។

បុគ្គលិកអង្គការចិត្តសង្គម អន្តរវប្បធម៌ (TPO) បានពន្យល់អំពីរោគសញ្ញានៃការប៉ះទង្គិចផ្លូវចិត្ត ដែលប្រជាជនអាចរងគ្រោះពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម។ ពួកគេបានផ្តល់ការប្រឹក្សាយោបល់ដល់អ្នកចូលរួមក្នុងវេទិកាជាច្រើនរូប។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែលគាំទ្រ និងផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណី បានសហការក្នុងការរៀបចំវេទិកានេះ ក្នុងនោះមាន សមាគមអាដហុក, មជ្ឈមណ្ឌលឯកសារកម្ពុជា, វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, មជ្ឈមណ្ឌលសម្រាប់យុត្តិធម៌ និងសន្តិភាព និងសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍។

“ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពជនរងគ្រោះ ដែលរៀបចំវេទិកានេះឡើង។ យើងខ្ញុំបានរង់ចាំការជំនុំជម្រះនេះជាយូរមកហើយ ហើយយើងខ្ញុំចង់ឲ្យអង្គភាពជនរងគ្រោះជួយអវតកក្នុងដំណើរឆ្ពោះទៅមុខដោយភាពយុត្តិធម៌”។

នេះជាការប្រកាសរបស់អ្នកចូលរួមម្នាក់ក្នុងពេលបិទវេទិកា នាថ្ងៃអាទិត្យ ទី២៥ ខែតុលានេះ។ អ្នកចូលរួមម្នាក់ទៀតបានច្រៀងចំរៀងមួយបទអំពីមន្ទីរស-២១ ឬ គុកទួលស្លែងដ៏ព្រៃផ្សៃ។

ក្នុងកម្មវិធីបិទវេទិកា លោក Paul Oertly អនុប្រធានអង្គភាពជនរងគ្រោះបានសង្កត់ធ្ងន់លើ សារៈសំខាន់នៃទំនាក់ទំនងរវាងមេធាវី និងដើមបណ្ដឹងរដ្ឋប្បវេណី។ "បងប្អូនមានសិទ្ធិក្នុងការទំនាក់ ទំនងជាមួយពួកគេ និងទទួលព័ត៌មានអំពីការអភិវឌ្ឍថ្មីៗក្នុងសំណុំរឿង ដែលបងប្អូនចូលរួម។ ផ្នែកមួយនៃការងាររបស់យើងខ្ញុំនៅអង្គភាពជនរងគ្រោះ គឺជួយបងប្អូនឲ្យមានទំនាក់ទំនងដ៏ជិតស្និត និងប្រកបដោយប្រសិទ្ធភាពជាមួយមេធាវីរបស់បងប្អូន"។ លោកក៏បានស្វាគមន៍ចំពោះមតិ-យោបល់ល្អៗទាក់ទងនឹងបញ្ហាសំណង ដែលបានលើកឡើង និងបានបញ្ជាក់ថា អវតកកំពុងពិចារណាយ៉ាងយកចិត្តទុកដាក់អំពីប្រភេទសំណង ដែលមានសារៈសំខាន់ និងមានលក្ខណៈសមស្របបំផុតសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី។

វេទិកាថ្នាក់តំបន់បន្ទាប់គ្រោងនឹងរៀបចំឡើងនៅរាជធានីភ្នំពេញក្នុងខែធ្នូខាងមុខនេះ។

**ការចូលរួមក្នុងពិធីបុណ្យកឋិនទាននៅខេត្តពោធិ៍សាត់**

ប្រជាជនរាប់រយនាក់ ដែលបានប្រមូលផ្ដុំសម្រាប់បុណ្យកឋិនមហាសាមគ្គីនៅវត្តពោធិ៍ល្វាំ ក្នុងភូមិពោធិ៍ល្វាំ ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់បានចូលរួមក្នុងសកម្មភាពមួយចំនួន ដែលបានរៀបចំឡើងដោយអាជ្ញាធរមូលដ្ឋាន, សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ រួមគ្នានឹងអង្គភាពជនរងគ្រោះ។

នៅល្ងាចថ្ងៃទី២១ ខែតុលាថ្មីៗនេះ ភ្ញៀវបានបង្អុរយ៉ាងយូរហូតដល់ពេលទស្សនាវគ្គទីមួយ នៃភាពយន្តឯកសារឈ្មោះ *ដល់ពេលរកយុត្តិធម៌* ដែលក្នុងនោះលោកប្រធានកិច្ចការសាធារណៈរបស់អវតកបានពន្យល់អំពីគោលបំណង និងការងាររបស់តុលាការដល់ក្រុមគ្រួសារមួយមកពីរាជធានីភ្នំពេញ។ ភាពយន្តឯកសារនេះត្រូវបានបញ្ចាំងនៅលើផ្ទាំងក្រណាត់ស ដែលព្យួរនៅចន្លោះដើមឈើ ផ្ដល់នូវការទាក់ទាញ ប្រកបដោយប្រជាប្រិយភាពមួយចំណែកទៀតដល់បុណ្យកឋិនទាននេះ។

នៅព្រឹកបន្ទាប់ លោក អ៊ឹម សាមិន មេឃុំត្រពាំងជង បានស្វាគមន៍ក្រុមការងារអវតកនៅក្នុងការប្រជុំមួយ មានប្រជាជនចូលរួមរាប់រយនាក់

ដែលនិយាយផ្តោតចំបងលើសារៈសំខាន់នៃអវតក ក្នុងការនាំមកនូវយុត្តិធម៌ ដែលប្រជាជនខ្មែររង់ចាំអស់រយៈពេលយ៉ាងយូរមកនេះ។ លោកស្រីបណ្ឌិត ហេឡិន ចារវិស ប្រធានអង្គភាពជនរងគ្រោះ បានគូសបញ្ជាក់អំពីតួនាទីរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធី ហើយ លោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ជេត វណ្ណលី បានពន្យល់អំពីតួនាទីមេធាវី ក្នុងការជួយគាំទ្រដល់ជនរងគ្រោះ។

“គេហៅយើង “យួន”ឬ “កម្ពុជាក្រោម” ហើយពួកយើងភាគច្រើនត្រូវបានគេយកទៅសម្លាប់” ។ “ខ្ញុំបាត់បង់ប្តី និងកូនៗខ្ញុំទាំងអស់។ ខ្ញុំនៅសល់តែម្នាក់ឯងគត់សព្វថ្ងៃ”។ ទាំងនេះជាពាក្យសំដីមួយ ចំនួន ដែលអ្នកចូលរួមរៀបរាប់អំពីទុក្ខវេទនា ដែលពួកបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោក មាស ច័ន្ទថន ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងសំណុំរឿង០០២ ដែលជាបុគ្គលិកម្នាក់នៃ សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ បានរៀបរាប់អំពីគ្រាដែលគាត់បានវិល ត្រឡប់មកភូមិរបស់គាត់វិញនាដើមឆ្នាំ១៩៧៩ គឺអ្វីៗត្រូវបានឆេះអស់សល់តែផេះផង់ ហើយវត្តត្រូវបានដុតបំផ្លាញ។ មានតែម្នាក់ប៉ុណ្ណោះក្នុងចំណោមសមាជិកគ្រួសារគាត់ទាំងប្រាំនាក់បានរស់រានមានជីវិត។ ក្រុមការងារក៏ត្រូវបានអញ្ជើញទៅទស្សនាវាលពិឃាត និងវិមានរំលឹកវិញ្ញាណក្ខន្ធក្នុងបរិវេណ នោះដែរ។

បុគ្គលិកអង្គភាពជនរងគ្រោះក៏បានចូលរួមក្នុងពិធីបុណ្យកឋិនទាន ដែលត្រូវបានផ្តួចផ្តើមដើម្បី ប្រមូលបច្ច័យកសាងវត្តពោធិ៍ល្បាំដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក នៅ កាស៊ី ប្រធានកម្មវិធីផ្សព្វផ្សាយរបស់អង្គភាព ជនរងគ្រោះ តាមរយៈលេខទូរស័ព្ទ ០១២ ៨១ ៨០ ៣៥។